# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0168**

## សម្ភាសជាមួយឈ្មោះ ទូច ភាន ភេទស្រី អាយុ៦៨ឆ្នាំ
## មុខងារខ្មែរក្រហមៈ “ពេទ្យទំនប់ត្រពាំងថ្ម”
## រស់នៅភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៥២:១៧
## ៣៥ទំព័រ

ដានី ៖ ជំរាបសួរមីងខ្ញុំចង់ស្គាល់ឈ្មោះមីង ឈ្មោះពេញឈ្មោះអីដែរ?

ភាន ៖ ឈ្មោះ ម៉ា ភាន ។

ដានី ៖ ឈ្មោះ ម៉ា ភាន?

ភាន ៖ ចា៎! ត្រកូល ទូច ភាន ។

ដានី ៖ មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

ភាន ៖ អានេះ៦៨ហើយ ។

ដានី ៖ មីងស្រុកកំណើតកើតជានៅណា?

ភាន ៖ នៅនេះឯង ប៉ោយសំរោង ។

ដានី ៖ ភូមិប៉ោយសំរោង?

ភាន ៖ ភូមិប៉ោយសំរោង ។

ដានី ៖ ឃុំអីដែរ?

ភាន ៖ ឃុំអី?

ដានី ៖ ឃុំព្រះនេត្រព្រះ?

ភាន ៖ ឃុំព្រះនេត្រព្រះ ។

ដានី ៖ ស្រុកអីគេ?

ភាន ៖ ស្រុកព្រះនេត្រព្រះដែរ ។

ដានី ៖ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ?

ភាន ៖ ចា៎! ខេត្ត(បន្ទាយ)មានជ័យ ។

ដានី ៖ ចុះសព្វថ្ងៃរស់នៅភូមិអីដែរ?

ភាន ៈ នៅប៉ោយសំរោង ។

ដានី ៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះដែរ?

ភាន ៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះដែរ ។

ដានី ៈ ចុះមីងប្ដីរបស់មីង គាត់ឈ្មោះអីទៅ?

ភាន ៈ ប្ដីខ្ញុំគាត់បែកបាក់គ្នាអស់ហើយ ដែលគាត់ទៅផ្សេង ខ្ញុំនៅតែខ្ញុំសព្វថ្ងៃ នៅតែឯង ជាមួយកូនជាមួយចៅ ។

ដានី ៈ បែកបាក់គ្នាយូរនៅ?

ភាន ៈ យូរហើយតាំងពី២០ឆ្នាំហើយ ។

ដានី ៈ បែកបាក់គ្នា២០ឆ្នាំ?

ភាន ៈ ចាំ!

ដានី ៈ គាត់ឈ្មោះអី?

ភាន ៈ ឈ្មោះ ឈួង ប៉ាន ឈួង ។

ដានី ៈ គាត់នៅ?

ភាន ៈ ដូនជ្រែង ។ គេបានប្រពន្ធទៀតហើយ គេឈប់រាប់អាន ។

ដានី ៈ ចុះមីងមានកូនចៅប៉ុន្មាននាក់?

ភាន ៈ អត់ៗ ។

ដានី ៈ អត់មានកូនទេ?

ភាន ៈ អត់ទេ ។

ដានី ៈ នៅម្នាក់ឯង?

ភាន ៈ នៅម្នាក់ឯងជាមួយប្អូន ។

ដានី ៈ ចុះសព្វថ្ងៃមីងប្រកបមុខរបររកស៊ីធ្វើអីដែរ?

ភាន ៈ អត់ទេ ខ្ញុំនៅនឹងប្អូនសុំសីលថ្ងៃ៨ ថ្ងៃដាច់ ក៏នៅលក់វាតិចតួចគ្រាន់ជួយវាដាំបាយដាំទឹកនៅ លើកគេទាំងអស់ អត់មានទៅទីពឹងអ្នកណា ។

ដានី ៈ នៅជាមួយប្អូនៗស្រី ប្រុស?

ភាន ៈ ស្រី ។

ដានី ៈ គាត់ឈ្មោះស្អី ប្អូនស្រី?

ភាន ៈ ឈ្មោះ នាង រើន ។

ដានី ៖ ឈ្មោះពេញ?

ភាន ៖ ទូច ទាំងអស់ ។

ដានី ៖ ទូច រើន?

ភាន ៖ ចា៎!

ដានី ៖ ចុះឪពុកមីងគាត់ឈ្មោះអីដែរ?

ភាន ៖ ឈ្មោះ តាផុន ។

ដានី ៖ ឈ្មោះ តាផុន?

ភាន ៖ ចា៎!

ដានី ៖ សព្វថ្ងៃគាត់នៅរស់ ឬខូចហើយ?

ភាន ៖ គាត់ខូសហើយ ។

ដានី ៖ ចុះម្ដាយ?

ភាន ៖ ម្ដាយឈ្មោះ តាំង ។

ដានី ៖ ម្ដាយឈ្មោះ តាំង?

ភាន ៖ ចា៎!

ដានី ៖ គាត់នៅរស់ ឬក៏ខូចហើយ?

ភាន ៖ គាត់ខូចអស់ហើយ ។

ដានី ៖ ចុះមីងបងប្អូនបង្កើតប៉ុន្មាននាក់?

ភាន ៖ ៤នាក់ ស្រីទទៃ(ទាំងអស់) ។

ដានី ៖ បងប្អូន៤នាក់ ស្រីទាំងអស់?

ភាន ៖ ស្រីទាំងអស់ ។

ដានី ៖ ចុះមីងកូនទីប៉ុន្មាន?

ភាន ៖ ទី១ ។

ដានី ៖ ចុះកាលពីក្មេងៗបានរៀនសូត្រអីដល់ថ្នាក់ណា?

ភាន ៖ ខ្ញុំមិនបានរៀនទេ រៀនត្រឹម មិនបានរៀនទេ ។

ដានី ៖ អត់ដែលបានទៅសាលារៀន?

ភាន ៖ អត់បានទៅសាលា ឪពុកម្ដាយក្រ ទៅរៀនហើយអត់មានអ្នកណាមើលបងមើលប្អូន ។

ដានី ៖ ចឹងមីងចេះអាន ចេះសរសេរ យើងអានសៀវភៅ?

ភាន ៖ អត់ចេះទេ ចុះសម័យនោះឃើញយើងចេះតែឲ្យ ។

ដានី ៖ ចុះមីងកាលពីក្មេងៗ អត់បានរៀនសូត្រអីចឹងនៅជាមួយឪពុកម្តាយ?

ភាន ៖ នៅជាមួយឪពុកម្តាយ ។

ដានី ៖ ចុះកាលនឹងធ្វើអីទៅ?

ភាន ៖ ធ្វើតែស្រែចំការ ។

ដានី ៖ ជួយគាត់ធ្វើស្រែចំការ?

ភាន ៖ ចាំ! ជួយស្រែចំការ ។

ដានី ៖ ដល់ពេលមីងជួយគាត់ធ្វើស្រែចំការដល់ពេលណា បានមីងដូចថាបែកពីគាត់?

ភាន ៖ បានគ្រួសារ ។

ដានី ៖ បានគ្រួសារឆ្នាំណា?

ភាន ៖ កាលបានគ្រួសារ ខ្ញុំអាយុ១៩ បែកពីគាត់១៩ ។

ដានី ៖ រៀបការពេលអាយុ១៩ឆ្នាំ?

ភាន ៖ ចាំ!

ដានី ៖ ឆ្នាំណា មីងចាំឆ្នាំ?

ភាន ៖ អត់ចាំទេ ខ្ញុំយូរហើយ ១៩កាលនោះ ។

ដានី ៖ ពេលអាយុ១៩ឆ្នាំនឹង កាលនឹងលន់ នល់ធ្វើរដ្ឋប្រហារហើយ ឬក៏មិនទាន់ទេ?

ភាន ៖ មិនទាន់ធ្វើទេដឹង ។

ដានី ៖ កាលមីងរៀបការនឹងមុន?

ភាន ៖ អត់ទាន់ទេ មានហើយ ។

ដានី ៖ អត់ទាន់ទេ មុនរដ្ឋប្រហារឆ្នាំ៧៥ ?

ភាន ៖ ចាំ!

ដានី ៖ ចឹងដល់ពេលមីងរៀបការហើយ យ៉ាងម៉េចទៀតទៅ មីងបែកផ្ទះ?

ភាន ៖ បែកផ្ទះទៅនៅជាមួយប្តីធ្វើស្រែ ធ្វើចំការដដែល ។

ដានី ៖ ធ្វើស្រែចំការនៅណាដែរ?

ភាន ៖ នៅជាមួយគ្រួសារ ។

ដានី ៖ ក្នុងភូមិណា?

ភាន ៖ ភូមិនេះហើយ បានប្តីភូមិប៉ោយសំរោង ។

ដានី ៖ នៅភូមិប៉ោយសំរោងដដែល?

ភាន ៖ ចាំ!

ដានី ៖ ប៉ុន្តែ បែកផ្ទះពីឪពុកម្តាយ?

ភាន ៖ ចាំ!

ដានី ៖ នៅភូមិយើងធ្វើស្រែ ហើយចំការគេធ្វើអីទៅ?

ភាន ៖ ចំការដាំឪឡឹក ដាំត្រសក់ ដាំសណ្តែក ដាំអីចេះតែដាំ ។

ដានី ៖ ចុះមីងធ្វើស្រែ ធ្វើចំការនឹងបានប៉ុន្មានទៅ បាន?

ភាន ៖ បានម៉ាហូបៗ ។

ដានី ៖ ប៉ុន្តែ ប្រមាណរយៈពេលប៉ុន្មានទៅ បានយើងស្រុកយើងមានសង្គ្រាម?

ភាន ៖ អូ! ខ្ញុំភ្លេចអស់ហើយ ដឹងសង្គ្រាមប៉ុន្មាន ខ្ញុំភ្លេចអស់ ។

ដានី ៖ ដល់ពេលឆ្នាំ៧៥ ពេលដែលប៉ុលពតចូលមកនឹង មីងចាប់ផ្តើមឲ្យធ្វើពេទ្យតែម្តង ឬក៏មិនទាន់ទេ?

ភាន ៖ អត់ទេ ខ្ញុំទៅកាប់ព្រៃកាប់អីគេចេះតែឲ្យធ្វើស្ទូងដកឲ្យឡើងចប់ បានឡើងយូរបានគេហៅទៅនៅត្រពាំងថ្ម ។

ដានី ៖ មីងអាចរៀបរាប់តិចបានទេ កាលនឹងប្តីរបស់មីង មីងចាប់ផ្តើមបែកឆ្នាំ៧៥ ពេលដែលប៉ុលពត ចូលមក កាលនឹងគ្រួសារមីងយ៉ាងម៉េច មីងធ្វើការយ៉ាងម៉េច?

ភាន ៖ បែកគ្នាហើយ គាត់ទៅណា មុខព្រួញផ្សេង ខ្ញុំមុខព្រួញផ្សេងអត់បានជួបគ្នា ។

ដានី ៖ ៧៥ បែកគ្នា?

ភាន ៖ ចាំ!

ដានី ៖ បែកគ្នា ប្តីគាត់ទៅណា?

ភាន ៖ ដឹងគាត់ទៅណា មុខព្រួញគាត់ផ្សេង កាលនោះដែលអ្នកណាហ៊ាននិយាយអី រឿងផ្សេងរៀងខ្លួន ។

ដានី ៖ គាត់កសាងនៅណា?

ភាន ៖ នៅចល័តដដែល នៅចល័តជាមួយគ្នា ។

ដានី ៖ ហើយប្តីទៅចល័តនៅណា?

ភាន ៖ ចល័តត្រពាំងថ្មជាមួយគ្នា ។

ដានី ៖ ចឹងតាំងពីឆ្នាំ៧៥ ?

ភាន ៖ ចា៎!ដែលភារកិច្ចផ្សេងគ្នា គាត់ខាងនេះទំនប់អីទៅវាស់ទំនប់អីទៅ ខ្ញុំភារកិច្ចទៅគេឲ្យនៅកន្លែង ស្រណុក ។

ដានី ៖ ខ្ញុំចង់បញ្ជាក់មីងតិច កន្លែងឆ្នាំ៧៥ ពេលដែលប៉ុលពតដែលយើងបាយរួមនឹង កាលនឹងមីង ទៅត្រពាំងថ្មភ្លាម ឬក៏យើងទៅធ្វើការកន្លែងណាផ្សេងសិន?

ភាន ៖ អត់ទេ នៅក្នុងភូមិឡើងយូរ ។

ដានី ៖ នៅក្នុងភូមិយូរ?

ភាន ៖ ចា៎! គេរើសៗឲ្យទៅក្ដាប់ឲ្យទៅបេះតែទៅៗ ក៏គេឲ្យទៅត្រពាំងថ្មៗ ។ គេលើកទំនប់ ខ្ញុំនៅ មើលដាំបាយឲ្យអ្នកជម្ងឺ ត្រពាំងថ្មនោះឯង ។

ដានី ៖ កាលហ្នឹងពេលដែលមីងនៅក្នុងភូមិនៅអីនឹង នៅជាមួយប្ដីមីង គាត់នៅជាមួយដែរ ហើយ ក៏គាត់អត់ទេ?

ភាន ៖ ក៏គេចូលមកក៏បែកគ្នាភ្លាម ។

ដានី ៖ បែកគ្នាភ្លាម?

ភាន ៖ ចា៎! បែកចេញទៅរៀងខ្លួន ។

ដានី ៖ ចុះប្ដីគាត់ចេញទៅណា?

ភាន ៖ ចេញទៅចល័តទៅអី គេបេះប្រើៗឲ្យធ្វើអីៗ ។

ដានី ៖ ចល័ត គាត់ចល័តនៅណា?

ភាន ៖ ចល័តជាមួយគ្នា ត្រពាំងថ្ម ទៅនេះទៅនោះបេះតែទៅ ។

ដានី ៖ ទៅឆ្ងាយៗពីផ្ទះ?

ភាន ៖ ចា៎! ទៅឆ្ងាយពីផ្ទះ ។

ដានី ៖ ឆ្ងាយៗនឹង រយៈពេលប៉ុន្មាន បានមកជួបមីងម្ដង?

ភាន ៖ ដឹងណាបានមកជួបទេ ភ្លេចអស់ហើយកាលនោះ ខ្វាចដងមិនសូវហ៊ាន ខ្ញុំភ្លេចភ្លាំង ។

ដានី ៖ ចឹងកាលមីងនៅក្នុងភូមិ គេឲ្យធ្វើអីទៅ?

ភាន ៖ កាលមុនដំបូង គេឲ្យដំរះមន ដំរះអីទៅធ្វើចំការស្ពងដកតិចតួចទៅ ដល់យូរៗគេជ្រើសរើស ទៅនេះទៅនោះ ចល័តទៅនេះទៅនោះក៏បេះទៅ ។

ដានី ៖ ដំរះអីគេ?

ភាន ៖ មន ដំរះឪឡឹក ត្រសក់ ។

ដានី ៖ ធ្វើចំការនឹង មានដំរះមន ដកស្ពងអីនឹងទៅ?

ភាន :　ដកស្ទូង ។

ដានី :　កាលនឹងមីងធ្វើប្រធាន ហើយក៏ធ្វើសមាជិកដូចយើង?

ភាន :　ខ្ញុំកាលនៅភូមិអត់បានធ្វើអី ។

ដានី :　អត់បានធ្វើអី?

ភាន :　ចា៎! គេគ្រាន់តែប្រើ ប្រធានគេប្រើឲ្យដិរះស្មៅ ដិរះអីទៅតាមភូមិប៉ុននោះ ។

ដានី :　ដិរះស្មៅតាមភូមិ អានឹងគេហៅកងអីគេ?

ភាន :　កងចល័ត ។

ដានី :　គេហៅកងចល័ត?

ភាន :　ចា៎!

ដានី :　ចឹងមីងមានប្តីហើយ ក៏គេឲ្យចូលកងចល័តដែរ?

ភាន :　ចា៎! ព្រោះខ្ញុំអត់កូននោះ មកអត់កូនដូចនារី និងយុវជន បែកផ្សេងគ្នាចុះ វាអត់មានកូន ។

ដានី :　កាលនឹងគេហៅកងចល័តអីគេ ចល័តភូមិ ឬក៏ចល័តឃុំ ចល័ត?

ភាន :　ចល័តភូមិនោះឯង បើនៅតាមភូមិ ។

ដានី :　ចល័តភូមិ?

ភាន :　ចា៎!

ដានី :　ភូមិអីគេ?

ភាន :　ចល័តដឹងជាភូមិអីគេ ចេះទៅនេះទៅនោះ ។

ដានី :　មិនមែនភូមិប៉ោយសំរោងទេ?

ភាន :　ដែលនៅ ប៉ោយសំរោងនឹងហើយ ។

ដានី :　ភូមិប៉ោយសំរោង កាលនឹងប្រធានចល័តឈ្មោះអីទៅ នៅប៉ោយសំរោង?

ភាន :　អត់បានស្គាល់ទេ កាលនោះ ។

ដានី :　អត់បានស្គាល់ទេ?

ភាន :　អត់បានស្គាល់ទេ គេប្រើៗ គេហៅទៅណាក៏ទៅ ដកស្ទូង ។

ដានី :　ចុះកាលនឹងយើងដកស្ទូងដកអី យើងហូបបាយរួម ឬក៏យើងហូបបាយនៅផ្ទះ?

ភាន :　រួមៗម៉ាភូមិទាំងអស់ ។

ដានី :　កាលនឹងហូបយ៉ាងម៉េចទៅម្ហូប អាហារ ដូចជាបាយ ឬក៏ម្ហូបយ៉ាងម៉េច មីងអាចរៀបរាប់កន្លែងនឹងតិចមើល?

ភាន ៈ មានអី គេចែកទៅតាមក្រុមទៅៗ បើកបបរ មិនមែនបាយទេ បបរទៅ ។

ដានី ៈ ហូបបបរ?

ភាន ៈ ចា៎!

ដានី ៈ ចុះម្ហូបបានម្ហូបអី?

ភាន ៈ ត្រីគេ យើងបានក៏សម្លហូបខ្លះទៅ ។

ដានី ៈ ស្លគេច្រើនស្លអីគេ?

ភាន ៈ ស្ងោរជ្រុំ ស្ងោរអី ពីដើមមិញអត់ដែលស្លរមានអីទេ ។

ដានី ៈ មាន ចឹងហូបចុកបានឆ្អែតទេ?

ភាន ៈ ឆ្អែត ឲ្យតែបានបបរ ។

ដានី ៈ ហូបបបរឆ្អែតដែរ?

ភាន ៈ ឆ្អែត បើមិនឆ្អែតទៅណា ។

ដានី ៈ ម៉ាថ្ងៃហូបប៉ុន្មានពេល?

ភាន ៈ ព្រឹកល្ងាច ។

ដានី ៈ ហូបតែពេលព្រឹកល្ងាច?

ភាន ៈ ចា៎!

ដានី ៈ ព្រឹកម៉ោងប៉ុន្មានចាប់ផ្ដើមហូប?

ភាន ៈ ម៉ោង១០ជាងទៅ គេជិះស្មោះម៉ោង១០ជាងហូបទៅ ។

ដានី ៈ ដល់ពេលល្ងាចម៉ោងប៉ុន្មានទៀត?

ភាន ៈ ល្ងាចដល់ម៉ោង៥ ។

ដានី ៈ យើងហូបតែ២ពេលទេ?

ភាន ៈ ចា៎! ២ពេល មិនមែន៣ទេ ។

ដានី ៈ ហូបតែ២ពេល ហូបបបរជាមួយសម្លទៅ?

ភាន ៈ បបរជាមួយសម្លទៅ ។

ដានី ៈ ចឹងឆ្អែតដែរ២ពេល យើងហូបតែបបរ?

ភាន ៈ មិនដឹងថាឆ្អែត យើងចេះតែស៊ូទៅ ។

ដានី ៈ ចុះអត់មាន ពេលយប់អីយើងមានផ្លែឈើ?

ភាន ៈ ទេ! មានស្អីទេ ។

ដានី ៖ ដូចចេក ដូចដាំដុំវិញផ្ទះ?

ភាន ៖ អានឹងគេយកទៅ បើគេចែកមកក៏បាន បើគេមិនចែកក៏អត់ ។

ដានី ៖ ចុះពេលព្រលឹមឡើង មុននឹងយើងចេញទៅធ្វើការ អត់មានហូបអីទ្រាប់ពោះ?

ភាន ៖ អត់មានអីទេ មិនមានទេ ។

ដានី ៖ ចុះកាលនឹងមីងនៅផ្ទះជាមួយក្រុមគ្រួសារ ឬក៏យើងនៅអី ពេលដែលយើងនៅកងចល័តភូមិហើយ?

ភាន ៖ នៅជាមួយ ចល័តភូមិនៅជាមួយគ្រួសារ ដល់ពេលគេចេញក្រៅទៅ ក៏គ្រួសារចេញ ខ្ញុំក៏ចេញទាំងអស់គ្នាទៅ ។

ដានី ៖ ឆ្នាំណាដែលមីងចេញទៅ?

ភាន ៖ ដឹងឆ្នាំណា ភ្លេច ។

ដានី ៖ មីងធ្វើចល័តភូមិបានរយៈពេលប៉ុន្មានដែរ ដូចថា?

ភាន ៖ បានម៉ាឆ្នាំប៉ុននោះឯង ។

ដានី ៖ ម៉ាឆ្នាំ?

ភាន ៖ ចាំ! បានម៉ាឆ្នាំ ។

ដានី ៖ បឹងបានម៉ាឆ្នាំ គេឲ្យចេញទៅណា?

ភាន ៖ ទៅចល័តៗចេញទៅ គេឲ្យចេញទៅស្ពានស្រែង ទៅអីរួច ។

ដានី ៖ អានឹងគេហៅចល័តអី ទៅស្ពានស្រែង?

ភាន ៖ ចល័ត កងចល័ត ។

ដានី ៖ កងចល័តអីគេអានឹង?

ភាន ៖ ចល័តដើរធ្វើការលើកទំនប់លើកប្រឡាយ ។

ដានី ៖ បានន័យថា កងចល័តរបស់ភូមិប៉ោយសំរោងទៀត ឬរបស់ឃុំ របស់ស្រុក របស់តំបន់?

ភាន ៖ មិនដឹងជាយ៉ាងណាទេ ចេះទៅគេឲ្យទៅប្រធាន គេឲ្យទៅក៏ទៅ នោះឯងចេញពីភូមិហើយមិនបានទៅគិតគូ គិតតែរឿងគេប្រើការងារទៅណា ចេះតែទៅ គេឲ្យធ្វើអីចេះធ្វើ ។

ដានី ៖ ចល័តឃុំ មីងបើតាមមីងស្មានមើលដំបូង ពេលមីងចេញទៅ មីងចាំ?

ភាន ៖ អត់ចាំទេ យូរហើយ ។

ដានី ៖ កាលនឹងយើងចេញពីភូមិទៅកងចល័តនៅណា ស្ពានស្រែង?

ភាន ៖ ទៅត្រពាំងថ្ម ។

ដានី ៖ ដំបូង ចេញពីភូមិដំបូងទៅត្រពាំងថ្មម៉ង ឬទៅកន្លែងណាផ្សេង?

ភាន ៖ ទៅពីស្ពានស្រែងទៅត្រពាំងថ្ម ស្ពានស្រែងបិទស៊ឹងកាលនោះ ។

ដានី ៖ ទៅបិទស៊ឹង?

ភាន ៖ ចាំ!

ដានី ៖ ចឹងចេញពីភូមិប៉ោយសំរោងទៅកងចល័តទៅស្ពានស្រែង?

ភាន ៖ ចាំ! ទៅស្ពានស្រែង មកពីស្ពានស្រែងមកត្រពាំងថ្ម ចប់ដល់យួនចូលតែម្តង ។

ដានី ៖ ទៅស្ពានស្រែងនឹង បិទស៊ឹងយ៉ាងម៉េច មីងអាចរៀបរាប់កន្លែងនឹងតិចមើល?

ភាន ៖ បិទឲ្យស៊ឹងវាជាប់ធ្វើផ្លូវដើរឆ្លងឆ្ងើយ ។

ដានី ៖ យើងទៅលើកទំនប់កាត់ស៊ឹង?

ភាន ៖ ចាំ!

ដានី ៖ កាលនឹងគ្នាប៉ុន្មាននាក់ ហើយលើករយៈពេលប៉ុន្មាន?

ភាន ៖ អូ! ច្រើនណាស់ មិនដឹងប៉ុន្មានទេ បើខ្ញុំ គ្រាន់តែខ្ញុំទៅនឹង ទៅចល័តនឹង គ្រាន់គេឲ្យលើកអា ទំនប់តូចៗទៅ គេអ្នកធំៗគ្នាទៅ ពួកខ្ញុំតាមកងចេះទៅលើកទំនប់តូចៗទៅ ។

ដានី ៖ បិទស៊ឹង គេហៅស៊ឹងអីគេ?

ភាន ៖ ដឹងស៊ឹងអីទេ ស៊ឹងស្ពានស្រែងដឹង ខ្ញុំមិនស្គាល់ផង ។

ដានី ៖ បិទស៊ឹង កាលនឹងរយៈពេលប៉ុន្មានទៅកាលនឹង?

ភាន ៖ អូ! យូរហើយ ។

ដានី ៖ ដូចថារយៈពេលដែលមីងទៅកន្លែងស្ពានស្រែង ទៅបិទស៊ឹងទៅធ្វើនៅនឹងបានរយៈប៉ុន្មាន បាន យើងផ្លាស់ចេញទៀត ។

ភាន ៖ ខ្ញុំ ប្រហែលបានម៉ាឆ្នាំនោះឯង បានទៅត្រពាំងថ្ម កាលនោះជាប់យួនចូល ។

ដានី ៖ អត់ទេ នៅស្ពានស្រែង ខ្ញុំអត់ទាន់សួរដល់ត្រពាំងថ្មទេ?

ភាន ៖ ស្ពានស្រែងនោះ ប្រហែលម៉ាឆ្នាំ ។

ដានី ៖ នៅប្រហែលម៉ាឆ្នាំដែរ?

ភាន ៖ ចាំ! ម៉ាឆ្នាំ ព្រោះនៅលើកទំនប់ប្រឡាយតូចៗ ។

ដានី ៖ លើកទំនប់ ប្រឡាយ?

ភាន ៖ ចាំ! ប្រឡាយតូចៗខ្វាត់ខ្វែង ។

ដានី ៖ ចុះកាលនឹងមីងអ្នកលើកធម្មតា ឬកាលនឹងមីងធ្វើអីមិនមែនដូចថាយើងមិនជាអ្នកដឹកនាំ ឬក៏យើងធ្វើជា?

ភាន ៖ ខ្ញុំធ្វើដូចថាប្រធាន អនុប្រធានគ្រាន់តែធ្វើតាមក្រុមលើកប្រឡាយតូចៗទៅណា ។

ដានី ៖ យើងធ្វើៗជាប្រធានអីគេ?

ភាន ៖ កូនក្រុមថាឲ្យ១០នាក់ ឲ្យលើកទំនប់ ប្រឡាយ ។

ដានី ៖ ក្តាប់១០នាក់ ធ្វើប្រធានក្រុម?

ភាន ៖ ចាំ! ធ្វើប្រធានក្រុម ១០នាក់លើកប្រឡាយទៅ ។

ដានី ៖ ចុះមីងកាលនឹងដូចថាយើងប្រធានក្រុម យើងដូចថាកាលនឹង គេប្រាប់គេដាក់ផែនការអីឲ្យយើងលើកទំនប់នឹង លើកយ៉ាងម៉េច ម៉ាថ្ងៃម្នាក់ៗប៉ុន្មាន?

ភាន ៖ ម៉ាម៉ែត្រគីប ម្នាក់ម៉ាថ្ងៃ ។

ដានី ៖ ពីណាគេ អ្នកប្រាប់មីងឲ្យមក?

ភាន ៖ ប្រធាន ដឹងប្រធាននៅណាគេប្រាប់ចឹង ។

ដានី ៖ ប្រធានអីគេ មកប្រាប់មីង?

ភាន ៖ ប្រធានក្រុម ប្រធានកងគេ មានដូចយើងសព្វថ្ងៃនេះ ប្រធានក្រុមប្រធានកងមានដូចសព្វថ្ងៃចេះឯង ។

ដានី ៖ កាលនឹងមីងខស្សរាប់ប្រជុំដែរ?

ភាន ៖ ប្រធានក្រុម អត់បានប្រជុំទេ ប្រជុំតែគេប្រធានធំ ។

ដានី ៖ ប្រជុំតែប្រធានធំ?

ភាន ៖ ចាំ!

ដានី ៖ គេប្រជុំជាមួយពីណា?

ភាន ៖ មិនដឹងពីណា បើខ្ញុំមិនស្គាល់គេ ហោទៅ ពួកខ្ញុំគ្រាន់តែថាស្អែកនេះត្រូវតែលើកម៉ាក្រុម១០នាក់ ក៏ម៉ាម៉ែត្រគីបៗវាស់រួចក៏មកផ្ទះ មកកន្លែងដេកទៅ ។

ដានី ៖ លើកម៉ាម៉ែត្រគីបៗ?

ភាន ៖ ចាំ! ម្នាក់ម៉ាម៉ែត្រគីប ។

ដានី ៖ លើកទំនប់តូចៗ?

ភាន ៖ ទំនប់តូចៗ ។

ដានី ៖ នៅកន្លែងស្ពានស្រែង?

ភាន ៖ ស្ពានស្រែង ។

ដានី ៖ ស្ពានស្រែងនៅណា?

ភាន ៖ ឯនោះ ទៅត្បូង ។

ដានី ៖ នៅខាងស្រុកភ្នំស្រុកវិញ មិនមែននៅព្រះនេត្រព្រះវិញ?

ភាន ៖ ចា៎!

ដានី ៖ ចុះកាលនឹងម៉េចដែរ យើងទៅដល់នឹង យើងលើកទំនប់លើកអី ហើយហូបចុកអីហើយយ៉ាងម៉េចដែរ?

ភាន ៖ គេចែករបប ។

ដានី ៖ របបម៉េច?

ភាន ៖ ចា៎! របបតាមក្រុម របបបាយម៉ាចានៗ ទៅក៏ហូបទៅ ។

ដានី ៖ បាយម៉ាចានៗ?

ភាន ៖ ចា៎! ព្រឹកក៏ម៉ាចាន ល្ងាចក៏ម៉ាចាន គេមានម្ហូបសម្លអីក៏ហូប គេមានអីក៏ហូប ដែលហ៊ាននិយាយ ចេះតស៊ូ គ្មានអ្នកណាតស៊ូដល់ខ្ញុំទៅ ។

ដានី ៖ ចេះតែតស៊ូ?

ភាន ៖ ចា៎! ខ្លាចខ្ញុំមិនស៊ូ ។

ដានី ៖ ប៉ុន្តែ ពេលមីងទៅលើកនឹង អត់ដែលបានជួបជាមួយប្តីមីង?

ភាន ៖ មិនសូវដែលបានជួបគ្នាទេ បើការកិច្ចផ្សេង ។

ដានី ៖ ប៉ុន្តែបានជួបដែរអត់?

ភាន ៖ យូរៗគាត់មកម្តង មកសួរខ្ញុំចេះចុះទៅ គាត់ទៅវិញ ។

ដានី ៖ គាត់នៅណា?

ភាន ៖ គាត់នៅចល័តដែរ តែចល័តនឹងវាបែកគ្នា ។

ដានី ៖ ចល័តគាត់ ចល័តអីគេ?

ភាន ៖ ចល័តគាត់នោះ វាស់តែទំនប់ៗឲ្យគេ ។

ដានី ៖ គាត់អ្នកទទួលខុសត្រូវខាងវាស់ទំនប់?

ភាន ៖ ចា៎! នៅខាងវាស់ គំរង់ទំនប់ ។

ដានី ៖ ទំនប់នៅណា?

ភាន ៖ ទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង ទំនប់អីសព្វណា ។

ដានី ៖ គាត់ធ្វើប្រធាន?

ភាន ៖ គាត់មិនបានធ្វើប្រធានទេ គ្រាន់តែគេបញ្ជាឲ្យយើងវាស់ៗទៅ គេអ្នកប្រធានគេបញ្ជាឲ្យវាស់ យើងអត់មានភារកិច្ចអី ។

ដានី ៖ គាត់អ្នកវាស់ទំនប់?

ភាន ៖ ចាំ!

ដានី ៖ គាត់ពីមុនមកគាត់ធ្វើជាងធ្វើអី បានគាត់ចេះវាស់ទំនប់ចេះអី?

ភាន ៖ អត់ទេ គាត់អត់ដែលធ្វើជាង តែគេឲ្យគាត់វាស់ទៅ ត្រង់ល្អ ទៅវាចេះឲ្យវាស់ ។

ដានី ៖ ចឹងកាលនឹងមីង អត់បាននៅជាមួយគាត់ នៅយើង?

ភាន ៖ អត់បាននៅជាមួយគ្នា ។

ដានី ៖ អត់បាននៅជួបជុំគ្នា?

ភាន ៖ ចាំ! អត់ទេ ។

ដានី ៖ ចុះរបបកាលនឹងរបបហូបចុកអី មីងថាពេលយើងចែករបបនឹងយ៉ាងម៉េច ហូបចុកពេលដែល មីងចេញពីស្រុកភូមិទៅធ្វើទំនប់នៅស្ពានស្រែង?

ភាន ៖ របបគេត្រឹមត្រូវ ១០នាក់ក៏បាយម៉ាឆ្នាំង ចែកតាមរបបម៉ាចានៗ បើថាមានម្ហូបអីក៏ដាក់ម៉ា តិចៗ ។

ដានី ៖ បាយយើងដាំទៅ យើងចែកម៉ាចានម្នាក់?

ភាន ៖ ចាំ!

ដានី ៖ ម៉ាចាននឹង?

ភាន ៖ ហូបព្រឹក ម៉ាចានហូបល្ងាច ។

ដានី ៖ ម៉ាចានព្រឹក ម៉ាចានល្ងាច ហូបឆ្អែតអត់ម៉ាចាន?

ភាន ៖ ចេះតែស៊ូទៅណា មិនឆ្អែត មិនដឹងធ្វើម៉េច ។

ដានី ៖ ជាទូទៅខ្ញុំអីហូបម៉ាចានហើយ យើងត្រូវថែមកន្លះចានទៀតបានឆ្អែត ហើយយើងបានម៉ា ចានចឹង ហើយយើងចង់ថែមអីតិចទៀតបានដែរអត់?

ភាន ៖ មានបានណា បើគេចែកឲ្យប៉ុននោះឯង ។

ដានី ៖ គេចែកឲ្យប៉ុននឹង?

ភាន ៖ គេចែកឲ្យប៉ុននឹងឯង ចេះតែហូបតស៊ូ ។

ដានី ៖ ចុះបើកយើងអត់ឆ្អែត ដូចមីងធ្វើប្រធានក្រុមអត់តវ៉ាថា ហ៎! កូនចៅខ្ញុំហូបអត់ឆ្អែត ឬខ្ញុំហូបអត់ឆ្អែតយើងត្រូវថែមអី តែមិនចឹងទេ ខ្ញុំលើកទំនប់អត់រួច?

ភាន ៖ អត់ទេ អត់ហ៊ានៗ

ដានី ៖ អត់ហ៊ាន?

ភាន ៖ អត់ហ៊ានទេៗ

ដានី ៖ ចុះគេមានដែលសួរនាំយើង ថាហូបឆ្អែតអីយ៉ាងម៉េចដែរអត់?

ភាន ៖ ពេលធ្វើការគេសួរថា យើងថាឆ្អែតហើយ ឆ្អែតហើយៗ បើមិនថាចុះ យើងទៅតាមតារណាៗ

ដានី ៖ ចុះគេសួរចឹង ក្រែងលគេចង់ឲ្យយើងហូបឆ្អែតដែរ?

ភាន ៖ ទេ! ចែករបបហើយ ប៉ុននោះៗហើយ ពិបាកតាមតារសួរគេៗ

ដានី ៖ គេសួរក្រែងលគេសួរសុខទុក្ខយើង ថាយើងហូបអត់ឆ្អែត យើងធ្វើការ?

ភាន ៖ គេសួរនោះ ទាល់យើងឆ្លើយថាវាឆ្អែតហើយ មិនហ៊ាននិយាយទៅទៀតៗ

ដានី ៖ ម៉េចចឹង បានអត់ហ៊ាននិយាយ?

ភាន ៖ ហ៊ាននិយាយណា បើខ្លាចគេៗ

ដានី ៖ ខ្លាចគេ?

ភាន ៖ ចា៎!

ដានី ៖ ម៉េចចឹងបានមីងខ្លាចគេ?

ភាន ៖ ខ្លាចបើអ្នកមិនដែលស្គាល់ទេសម័យនោះៗ មិនខ្លាចគេទេណាៗ

ដានី ៖ សម័យនោះម៉េច មីងអាចរៀបរាប់ ពីព្រោះខ្ញុំអត់បានឆ្លងកាត់?

ភាន ៖ វាខ្លាចគេធ្វើប្រធានថាឯងតាមតារអី ឲ្យប៉ុនណាក៏ហូបប៉ុននោះទៅ ចាំបានទៅក៏វីឯងៗ

ដានី ៖ យើងតាមតារទៅវាមាន ដូចថាពេលដែលយើងតាមតារអីវាមានផលវិបាកយ៉ាងម៉េច ដូចថាឥឡូវនឹង ឧបមាថាឥឡូវ យើងប្រធានឃុំប្រធានភូមិគាត់នេះអីយើងអត់ត្រូវ យើងតាមតារគាត់ថាធ្វើចេះមិនត្រូវធ្វើចោះមិនត្រូវ គួរធ្វើចេះអី អត់អីទេៗ ប៉ុន្តែ កាលពីសម័យមីងដូចថាមីងធ្វើប្រធានក្រុម ប្រធានអីនឹង បើសិនណាយើងតាមតារទៅវាម៉េច?

ភាន ៖ ខ្លាចៗ បើយើងខ្លាចៗ

ដានី ៖ ខ្លាចគេធ្វើអី?

ភាន ៖ ខ្លាចគេដឹងគេធ្វើ ចេះតែខ្លាច ដឹងគេធ្វើរម៉េច ទាស់តែខ្លាចៗៗ

ដានី :	គេមានចាប់ដាក់ទោសយើងអីដែរ យ៉ាងម៉េច កាលជំនាន់នឹង?

ភាន :	ដឹងទោសយ៉ាងណា បើខ្ញុំមិនដែលបានដឹងផង ចេះតែខ្លាច ។

ដានី :	ចុះមានមូលហេតុអីបានមីងខ្លាច ដូចថាយើងមិនត្រូវសួរ?

ភាន :	មានមូលហេតុ គេថាកុំពិបាក ឆ្លើតប៉ុនណាក៏ហូបប៉ុននោះទៅ គេថាចុះហើយស្តាប់គេទៅ ។

ដានី :	ចុះកាលជំនាន់នឹងគេមានចាប់ មានអីយកទៅដាក់គុកឬក៏យកទៅសម្លាប់ដែលអត់កាលមីងធ្វើទំនប់?

ភាន :	ទេ! គ្រាន់តែកសាងតិចតួច ។

ដានី :	គេគ្រាន់ តែកសាងតិចតួច?

ភាន :	ចា៎!

ដានី :	គេអត់សម្លាប់ទេ?

ភាន :	អត់ទេ ។

ដានី :	គេអត់ដាក់គុក?

ភាន :	ទេ! ខ្ញុំមិនដឹងផង បើខ្ញុំនៅចល័ត មិនសូវមានរឿងហេតុចុះៗ ទេ ។

ដានី :	កសាងយ៉ាងម៉េច បើយើងខុសអី ឧបមាថាក្អួង?

ភាន :	កសាងហូបឆ្អែត មិនឆ្អែតម៉េចនៅតែស្ងៀមទៅ ខ្វះខាតចេះចុះក៏យើងចេះអធន ។

ដានី :	ចុះមីងនៅតែធ្វើការនៅស្ពានស្រែងបានម៉ាឆ្នាំ បានផ្លាស់ទៅត្រពាំងថ្ម?

ភាន :	ត្រពាំងថ្ម ។

ដានី :	កន្លែងនឹងដូចថាម៉េច បានគេផ្លាស់មីងពីស្ពានស្រែងទៅត្រពាំងថ្ម?

ភាន :	គេឲ្យទោសម្រាក ព្រោះខ្ញុំវាយ៉ាប់ៗ វាធ្វើការយ៉ាប់មុនដំបូង គេនឹកឃើញស្រណោះៗថា យើងទៅនៅកន្លែងនោះទៅវាស្រណុក គ្រាន់តែដាំបាយឲ្យគេ មើលគេ ។

ដានី :	ចុះមីងកាលផ្លាស់ទៅត្រពាំងថ្ម មីងធ្វើអី?

ភាន :	ខ្ញុំមានធ្វើអី ដាំបាយឲ្យអ្នកជម្ងឺ ដែលអីផង ។

ដានី :	មីងទៅដាំបាយឲ្យអ្នកជម្ងឺ?

ភាន :	ចា៎!

ដានី :	ទៅដាំបាយយ៉ាងម៉េច មីងអាចរៀបរាប់ ថាមីងទៅត្រពាំងថ្មនឹង ទៅអន្តភាពអីគេទៅ?

ភាន :	អន្តភាពនៅពេទ្យត្រពាំងថ្ម នៅជួយដាំបាយដាំទឹក ។

ដានី :	មីងផ្លាស់ទៅត្រពាំងថ្ម ចូលទៅអន្តភាពពេទ្យវិញ?

ភាន ៖ ចាំ!

ដានី ៖ កាលនឹងនៅអង្គភាពពេទ្យ មានគ្នាប៉ុន្មាននាក់?

ភាន ៖ អូ! ច្រើនណាស់គេ គ្រាន់តែគេឲ្យយើងទៅជួយរោម(ជុំ)គ្នា គ្រាន់ជួយដាំបាយដាំទឹក ។

ដានី ៖ ប៉ុន្តែមីងចាំថា ប៉ុន្មាននាក់ទៅអង្គភាពពេទ្យ?

ភាន ៖ អូ! ច្រើនណាស់ ។

ដានី ៖ ច្រើនប៉ុន្មាន ប្រហែលប៉ុន្មាន?

ភាន ៖ ប្រហែល៨-១០នាក់ ។

ដានី ៖ ប្រហែល៨-១០នាក់?

ភាន ៖ ចាំ!

ដានី ៖ ចុះពេទ្យនឹងមានតួនាទីអីខ្លះទៅ?

ភាន ៖ មានអី មានតែឲ្យថ្នាំលេប ដឹងថ្នាំអី ដាំបាយឲ្យអ្នកជម្ងឺដែលឈឺយ៉ាប់ៗ ទៅក៏ដាំបាយឲ្យហូប ទៅ អ្នកណាជាក៏ចេញទៅ ។

ដានី ៖ ឲ្យថ្នាំអ្នកជម្ងឺ?

ភាន ៖ ចាំ!

ដានី ៖ ដាំបាយឲ្យអ្នកជម្ងឺដែរ?

ភាន ៖ ចាំ! ដាំបាយឲ្យអ្នកជម្ងឺ ។

ដានី ៖ កាលនឹង១០នាក់ពេទ្យនឹង អត់មានចាក់ថ្នាំចាក់អីទេ មានតែឲ្យថ្នាំ?

ភាន ៖ ចាក់ៗអី ឲ្យថ្នាំឲ្យអីដាំបាយជួយមើលអ្នកជម្ងឺឈឺអីយប់ព្រលប់ ទៅយាមគ្នាមើលអ្នកជម្ងឺ ម្នាក់ម៉ាម៉ោង ២ម៉ោងក៏មកដេកផ្លាស់ហៅគ្នាជួយអ្នកជម្ងឺឈឺយប់ថ្ងៃ ផ្លាស់គ្នា ។

ដានី ៖ ក្នុងពេទ្យ១០នាក់នឹង យើងមើលអ្នកដែលមកវែកដីនៅអាងត្រពាំងថ្មទាំងអស់?

ភាន ៖ ចាំ! ម៉ាអាងត្រពាំងថ្ម ។

ដានី ៖ ចឹង១០នាក់នឹងពីណាធ្វើប្រធាន មីង?

ភាន ៖ មិនស្គាល់គេទេ ស្រុកគេ ខ្ញុំម្នាក់ឯងទៅ ។

ដានី ៖ មិនមែនមីងធ្វើក្នុង១០នាក់នឹងទេ?

ភាន ៖ ទេ! មិនបានធ្វើទេ ទៅដល់មន្ទីរពេទ្យមិនបានធ្វើទេ ។

ដានី ៖ អត់បានធ្វើប្រធានទេ?

ភាន ៖ ចាំ!

ដានី : ចឹង១០នាក់នឹង ប្រធានគេឈ្មោះអី?

ភាន : មិនស្គាល់គេទេ ទៅនៅស្រុកគេដទៃ ខ្ញុំម្នាក់ឯង ។

ដានី : ស្រុកណា ស្រុកដទៃ?

ភាន : ស្រុកអីស្រុកណា ខ្ញុំមិនដែលបានសួរ ទៅចល័តទៅទាំងអស់គ្នា មិនដែលបានសួរស្រុកស្រែ ថាគេនៅណានៅណែទេ ។ សម័យនោះតែទៅហើយ វាជួបគ្នាស្គាល់គ្នា ។

ដានី : ចឹងមីងទំនប់ត្រពាំងថ្មនឹង ពីដើមទំនប់ដល់ចុងទំនប់នឹង ចាប់ពីកន្លែងណាដល់កន្លែងណាទៅ?

ភាន : ខ្ញុំមិនសូវដែលបានទៅផង គ្រាន់ទៅមើលថ្ងៃនេះចង់ទៅមើលទំនប់គេ ក៏លើកទៅម៉ាក្អែត ដើរ មើលតាម អ្នកស្គាល់ៗខ្ញុំមកវិញ ។

ដានី : ចុះមីងដឹងប្រវែងប៉ុន្មានទំនប់ត្រពាំងថ្ម?

ភាន : អត់ៗដឹងផង ។

ដានី : ចុះទទឹងខ្នងទំនប់?

ភាន : ខ្ញុំក៏មិនដែលដឹងដែរ ក្រែងមីងធ្លាប់ដើរលេង ទៅមើល ។

ដានី : ដើរលេងយើងអាចឃើញថាទំនប់នឹងប្រហែលប្រវែងប៉ុន្មាន ទទឹងប៉ុន្មាន បណ្ដោយប៉ុន្មាន?

ភាន : អត់ដែលបានទៅទេ សព្វថ្ងៃគេទៅលេងឡើងខ្ញុំមិនដែលបានទៅទេ ចាស់ ។

ដានី : អត់ទេ កាលពេលមីងកំពុងតែលើកអី ពេលធ្វើពេទ្យអី ប៉ុនក្រែងយើងដើរព្យាបាលឲ្យថ្នាំទៅ អ្នកជម្ងឺនៅទំនប់នឹង?

ភាន : ចា៎!

ដានី : តើមីងដើរនឹង អាចប៉ាន់ស្មាន?

ភាន : ដើរក៏មិនបានបែងចែកថា ទំនប់នោះប៉ុន្មានអីប៉ុន្មានទេ ។

ដានី : យើងអាចស្មានមើលថាទំនប់នោះទទឹងប៉ុន្មាន ហើយបណ្ដោយយើងដើរធ្លាប់ដើរពីដើមទំនប់ រហូតដល់ចុងទំនប់អីប្រហែលប៉ុន្មានគីឡូអីមីង?

ភាន : អត់ដែលបានទៅទេ អត់ដែលបានពិចារណាចុះទេ គេលើកប៉ុន្មានអីប៉ុន្មាន តែភារកិច្ចយើងធ្វើ អីយើងធ្វើនោះ អាគេធ្វើអីធ្វើនោះក៏មិនបានប៉ុន្មានដែរ ។

ដានី : ចុះពេទ្យកាលនឹងយើងសំបូរអ្នកជម្ងឺទេ?

ភាន : សំបូរគ្រាន់នឹងឯង ប៉ះត្រង់ណាក៏សំបូរ ។

ដានី : អ្នកជម្ងឺរែកដីនឹង?

ភាន : រែកដី ។

ដានី ៖ វែកដីទៅគាត់ឈឺអី?

ភាន ៖ គ្រុនទៅ ចុះ(ចុក)ទៅរិលមុខរិលមាត់ទៅ។

ដានី ៖ គ្រុន?

ភាន ៖ ចាំ!

ដានី ៖ គ្រុនម៉េច ចុះម៉េច?

ភាន ៖ ចុះ(ចុក)អាចម៍។

ដានី ៖ រាគអាចម៍?

ភាន ៖ រាគអាចម៍ រាគអីប៉ុននោះ។

ដានី ៖ រាគអាចម៍ ហើយនឹងរិលមុខនឹង?

ភាន ៖ ចាំ! ប៉ុននោះឯង។

ដានី ៖ ដល់ពេលគ្រុនយើងឲ្យថ្នាំឲ្យគាត់លេប?

ភាន ៖ ថ្នាំអីគេ ថ្នាំស១ ថ្នាំបាត់គ្រុន ថ្នាំបាត់ចុកបែកទៅ។

ដានី ៖ ពីណាអ្នកប្រាប់?

ភាន ៖ ពេទ្យអ្នកប្រាប់។

ដានី ៖ ពេទ្យណា?

ភាន ៖ ពេទ្យនៅជាមួយគ្នា ដែលស្គាល់គេ។

ដានី ៖ ឈ្មោះអី?

ភាន ៖ មិនស្គាល់ទេ ថានៅស្រុកផ្សេងគ្នាអត់បានស្គាល់គេទេ។

ដានី ៖ អត់ស្គាល់គេទេ?

ភាន ៖ ចាំ!

ដានី ៖ អ្នកជម្ងឺច្រើនជម្ងឺរិលមុខ?

ភាន ៖ ចុះ(ចុក)អាចម៍ទៅ ក៏គ្រុន។

ដានី ៖ រាគ គ្រុន?

ភាន ៖ ចាំ!

ដានី ៖ ច្រើនទេ ប្រហែលម៉ាថ្ងៃប៉ុន្មាននាក់ទៅ មកពេទ្យ?

ភាន ៖ មាន២នាក់ ពេទ្យធំគេដើរចុះតាមកន្លែងច្រើន បើខ្ញុំនៅដាំបាយ មិនដឹងជាប៉ុន្មាន។

ដានី ៖ ចុះមីងនៅដាំបាយផង បែកថ្នាំផង?

ភាន : ចា៎!

ដានី : ដាំបាយឲ្យពេទ្យគ្នា១០នាក់នឹង?

ភាន : ឲ្យអ្នកជម្ងឺ ។

ដានី : ឲ្យអ្នកជម្ងឺទៀត?

ភាន : ចា៎!

ដានី : ដាំបាយប៉ុន្មានឆ្នាំងទៅ ឲ្យអ្នកជម្ងឺ?

ភាន : ដាំម៉ាឆ្នាំងធំ ។

ដានី : ម៉ាឆ្នាំងប៉ុន្មានកំប៉ុងដាំម្តង?

ភាន : ១០ ។

ដានី : ១០កំប៉ុង?

ភាន : ចា៎!

ដានី : សម្រាប់អ្នកជម្ងឺប៉ុន្មាននាក់?

ភាន : អ្នកជម្ងឺសុទ្ធតែខ្ទះ បាយ៣ខ្ទះធំៗ ។

ដានី : ៣ខ្ទះធំៗ?

ភាន : ចា៎!

ដានី : ចុះមីងមានប្រសាសន៍មិញ មីងថាមីងដាំបាយឲ្យអ្នកជម្ងឺ?

ភាន : ដាំបាយឲ្យអ្នកជម្ងឺផង ដាំបាយឲ្យពេទ្យផងខ្ញុំ ។

ដានី : ចុះដាំបាយតែ១០កំប៉ុងទេ?

ភាន : ដាំបាយពេទ្យ១០កំប៉ុង ដាំបាយអ្នកជម្ងឺ៣ខ្ទះ ។

ដានី : មីងដាំម្នាក់ឯង?

ភាន : ដាំម្នាក់ឯង កូនចៅជួយខ្លះ ។

ដានី : កូនចៅជួយខ្លះ?

ភាន : ចា៎!

ដានី : មីងមានកូនចៅប៉ុន្មាននាក់?

ភាន : ទេ! កូនចៅចល័តនៅនោះ ។

ដានី : បាទ! កូនចៅចល័ត មីងធ្វើមេក្រុមគេ ហើយកូនក្រុមមីងប៉ុន្មាននាក់បានជួយដល់មីង?

ភាន : ដឹងប៉ុន្មានទេ ច្រើនដែរ បើចេញចូលៗចុះច្រើនគ្នា ក៏មិនដឹងថាប៉ុន្មាន ចេះជួយគ្នាទៅចុះ ។

ដានី ៖ ចុះដាំបាយហើយយើងស្លទៀត?

ភាន ៖ គ្មានអីទេ អំបិលៗគ្រោះដាក់ចាន ចែកទៅតាមដួប ។

ដានី ៖ ចឹងកាលនឹងយើងដាំបាយហើយមិនបាច់ស្លទេ យើងយកអំបិលមក យើង?

ភាន ៖ អំបិលមកចែកម៉ាចឹបៗទៅ ។

ដានី ៖ ចឹងបាយជាមួយអំបិល?

ភាន ៖ ចាំ! បាយជាមួយអំបិល ។

ដានី ៖ យើងអត់មានស្លអីទេ?

ភាន ៖ អត់ទាន់មានទេ បើថ្ងៃណាបានត្រីមកពីក្រោមមកក៏បានដាក់ស្លទៅ បើថ្ងៃណាអត់ក៏អំបិលទៅ ។

ដានី ៖ ចឹងស្រួលដែល យើងដាំបាយ យើងចែកអំបិល យើងមិនសូវហត់ទេ?

ភាន ៖ មិនហត់ទេ ។

ដានី ៖ យើងធ្វើត្រីធ្វើអី ហើយក៏?

ភាន ៖ ដាំតែទឹកតែពុះទៅ ។

ដានី ៖ ឬក៏ចិតបន្លែចិតអីធ្វើស្ល យើងគ្រាន់ដាំបាយឆ្អិនហើយយើងចែកអំបិកម៉ាចឹបៗគ្នា?

ភាន ៖ ចាំ! ចែកអំបិលគ្នា១០នាក់ ក៏ដើរចែកគ្នា ។

ដានី ៖ ចុះពេទ្យក៏ហូបបាយជាមួយអំបិលដែរ?

ភាន ៖ ពេទ្យគេគ្នាគេ អាអ្នកធំៗគេដឹងគេស៊ីអី បើយើងអ្នករាយរង យើងស៊ី អាណាស៊ីទៅ ពេទ្យគ្នាគេចេញចូលសប្បាយដឹងមិនដែរ ។

ដានី ៖ ទៅណា?

ភាន ៖ ប្រហែលគេទៅស្វាយឡើងចុះៗមើលគ្នា ។

ដានី ៖ ចុះមីងហូបអី?

ភាន ៖ ខ្ញុំក៏អំបិលដូចតែគ្នា ថ្ងៃណាក៏បានត្រីទៅ គេដឹកត្រីដឹកប្រហុកទៅក៏បានហូបទៅ ។

ដានី ៖ ដល់ពេលបានត្រីយើងស្លអី?

ភាន ៖ ស្ងោរ ស្ងកររៀង ទៅបេះឯព្រៃ ។

ដានី ៖ ស្ងកររៀង?

ភាន ៖ ចាំ! ទៅបេះឯព្រៃណា ។

ដានី ៖ ឆ្អែតដែរ?

ភាន ៈ ទេ! បើចល័តខ្ញុំម៉ាចានបានហើយ មិនពិបាកយកច្រើនទេ ម៉ាចានៗ ។

ដានី ៈ មិនបាច់ច្រើន?

ភាន ៈ ចា៎!ម៉ាចានៗ អំបិលម៉ាចុបៗដាក់ទៅ ។

ដានី ៈ ចុះអ្នកជម្ងឺគេឲ្យហូបយ៉ាងម៉េចដែរ?

ភាន ៈ អំបិលនោះឯងចែក ។

ដានី ៈ ចែកអំបិលដែរ?

ភាន ៈ ចា៎!

ដានី ៈ ចុះអ្នកទោស(អ្នកជម្ងឺ) គេឲ្យហូបបាយដែរ ឬក៏ឲ្យហូបបបរ?

ភាន ៈ បាយៗ អ្នកជម្ងឺ បាយ ទាល់បំនិនឲ្យហូប ។

ដានី ៈ ចែកម៉ាចានៗ?

ភាន ៈ ចា៎! ម៉ាចាន ។

ដានី ៈ ម៉ាចានប៉ុនណា?

ភាន ៈ ម៉ាចានធំគ្រាន់ដែរ ។

ដានី ៈ បានចាប់ប៉ុននេះអត់ ចាន?

ភាន ៈ បាន ។

ដានី ៈ ហើយដាក់បាយប៉ុនណា ពេញម៉ានឹង?

ភាន ៈ ដាក់បាយក៏ ពេញៗម៉ានេះឯង ។

ដានី ៈ ពេញយើងដួសដាក់ៗទៅ?

ភាន ៈ ចា៎! ដួសដាក់ ឲ្យអន្ទុយដួរដូចលោកចឹង ។

ដានី ៈ ចុះមឹងពេលយើងដួសបាយឲ្យនឹង ឧបមាថាអ្នកណាចូលចិត្តយើងដួសឲ្យច្រើន អ្នកណាអត់ស្គូវចូលដួសកន្ទះ?

ភាន ៈ អត់ទេ ចានវិល(វាស់) ស្មើតែគ្នា ស្រណោះទាំងអស់គ្នាឯង បានចែកបាយម៉ាចានអំបិលម៉ាចុបៗគ្រប់គ្នា ។

ដានី ៈ បាយម៉ាចាន អំបិលម៉ាចុប?

ភាន ៈ ចា៎! គេហូបអីក៏ហូបទៅ ។

ដានី ៈ ចុះអ្នកនោះអត់តវ៉ាថា ហ៎! ខ្ញុំហូបបាយជាមួយអំបិលហូបអត់ចូលទេ ចង់រកសាច់អី?

ភាន ៈ អូ! អត់មានទេ អត់មានតវ៉ាបានទេ ។

ដានី :	អត់មានតវ៉ាបាន?

ភាន :	ស្ដីក៏ហួបដែរ ។

ដានី :	ដឹងតែហួប?

ភាន :	ចា៎!

ដានី :	ចុះកាលនឹងពេលដែលមីងទៅអាងត្រពាំងថ្ម មិនជួបប្ដីមីង គាត់មិនធ្លាប់នៅវាស់ទំនប់នៅត្រពាំងថ្ម?

ភាន :	ទេ! អត់ដែលបានជួបគ្នាទេ គាត់នៅតែគាត់ ខ្ញុំនៅតែខ្ញុំ ។

ដានី :	អត់នៅជាមួយគ្នា?

ភាន :	អត់នៅជាមួយគ្នា ។

ដានី :	ចុះមីងទៅត្រពាំងថ្ម នៅកន្លែងតែមួយ ហើយអត់នៅជាមួយគ្នាទៀត?

ភាន :	អត់ ចុះបើគាត់មិនដែលនៅគាត់ដើរតែចល័ត គាត់ដើរវាស់ៗតិចស្រុក ។

ដានី :	ចុះពេលយប់អី យើងមកគេងជាមួយគ្នា?

ភាន :	អត់ មិនដែលបាននៅជាមួយគ្នា ។

ដានី :	អត់ដែលបាននៅជាមួយគ្នា?

ភាន :	អត់ ។

ដានី :	រយៈពេលប៉ុន្មាន បានជួបគ្នាម្ដងៗ?

ភាន :	ដឹងប៉ុន្មានបានជួបទេ ភ្លេចអស់ហើយ វាយូរឆ្នាំអស់ទៅហើយ ។

ដានី :	ចុះមីងអ្នកជម្ងឺដូចជម្ងឺវិលមុខ រាគ ជម្ងឺគ្រុនអីនឹង ភាគច្រើនពេលមកព្យាបាលកន្លែងមីង គាត់ជាត្រឡប់ទៅធ្វើការវិញ ឬក៏គាត់ស្លាប់?

ភាន :	នៅតាមៗសាលា ទុកម៉ាជួរៗ ក៏ដើរឲ្យទៅ ដូចថាថ្នាំនេះគេថាអ្នកត្រូវតែចាក់ក៏យើងចាក់ថ្នាំអីៗ ។

ដានី :	មីងចេះចាក់ដែរកាលនឹង?

ភាន :	ចេះ អត់អីទេ អត់ខូចខាតទេ គេបង្ហាប់ខ្ញុំបង្ហាប់ថាបើចាក់សាច់ដុំត្រូវចាក់ត្រង់នេះ ចាក់ក៏មិន ដែលមានខូចខាតអ្នកណាមួយទេខ្ញុំ ។

ដានី :	ចាក់យកអីចាក់?

ភាន :	សារាំងយើង ។

ដានី :	សារាំងនឹង ប៉ុន្តែថ្នាំនឹងថ្នាំអី?

ភាន ៖ ថ្នាំមានថ្នាំអំពូល មានទឹកលឿង ទឹកក្រហម ។

ដានី ៖ គេមានចាក់ទឹកដូងដែរអត់?

ភាន ៖ ចាក់ទឹកដូងដែរ អត់អីទេខ្ញុំ ។

ដានី ៖ ទឹកដូងយកបូមដាក់ក្នុងសារ៉ាំងចាក់?

ភាន ៖ ចាំ! បូមសារ៉ាំងចាក់តាមសរសៃរ អានោះចាក់សរសៃរ ខ្ញុំអត់មានខូចខាត ឡើងចប់គ្នាដទៃ គេឲ្យចាក់អត់មានអីទេ ។

ដានី ៖ មីងមើលទៅអ្នកជម្ងឺដែលយើងចាក់ទៅ គាត់ជា គាត់បានទៅធ្វើការវិញ ឬក៏?

ភាន ៖ ជា ដែលនៅយូរៗទៅក៏ហូបបានសម្រាកបានក៏ជាចេញទៅ ដែលខ្ញុំសុំចេញទៅឲ្យទៅប្រាប់ អ្នកធំទៅក៏ឲ្យចេញទៅ ។

ដានី ៖ អ្នកធំឈ្មោះអី?

ភាន ៖ មិនស្គាល់នឹង សុទ្ធផ្សេងគ្នាដទៃ ដូចជាភូមិមួយៗទៅនៅជាមួយគ្នា ភូមិនេះភូមិនោះ ។

ដានី ៖ អ្នកជម្ងឺច្រើនដែលនៅពេទ្យនឹង ប្រហែលប៉ុន្មានកាលនោះ?

ភាន ៖ កាលនឹង២-៣សាលា ប្រហែល ។

ដានី ៖ ប្រហែលប៉ុន្មាន?

ភាន ៖ ប្រហែល១០០នាក់ ។

ដានី ៖ ចុះអ្នកដែលទៅលើទំនប់ត្រពាំងថ្មនឹង គ្នាប៉ុន្មានទៅ?

ភាន ៖ អូ! ច្រើនណាស់ ។

ដានី ៖ ច្រើនប៉ុន្មាន?

ភាន ៖ ដឹងប៉ុន្មាន បើមិនបានទៅមើល បើថាច្រើនៗ បើលើកទំនប់ឡើងរួចអស់ធំប៉ុនណាប៉ុនណែ ។

ដានី ៖ ធំទំនប់នឹង?

ភាន ៖ ធំ ។

ដានី ៖ គ្នាច្រើន?

ភាន ៖ សព្វថ្ងៃគេទៅលេងនោះឯង ខ្ញុំអត់បានទៅទេ ច្រើននោះឯង ។

ដានី ៖ សព្វថ្ងៃគេទៅលេង?

ភាន ៖ ចាំ!

ដានី ៖ ចុះមីងអ្នកគ្រប់គ្រងទំនប់ត្រពាំងថ្ម គាត់ឈ្មោះអី?

ភាន ៖ មិនស្គាល់ដែលនឹង អត់ដែលបានទៅបានស្គាល់គេ ។

ដានី :	អ្នកធំគេដូចថាអ្នកដើរគ្រប់គ្រង អ្នកមើលការខុសត្រូវនៅនឹង?

ភាន :	មិនដឹងទេ មិនបានស្គាល់ទេ ។

ដានី :	អត់ដឹង?

ភាន :	អត់ សុទ្ធតែស្រុកគេ ស្រុកឯណាទេ ។

ដានី :	តែស្រុកគេក៏ដោយ តែមីងធ្វើការជាមួយគ្នា យើងស្គាល់គ្នា ស្គាល់ឈ្មោះស្គាល់អី?

ភាន :	ស្គាល់ គ្រាន់តែស្គាល់អត់បាននិយាយគ្នា ។

ដានី :	ស្គាល់ឈ្មោះគាត់ឈ្មោះអី?

ភាន :	វាមិនស្គាល់ទេ ភ្លេចអស់ហើយសព្វថ្ងៃៗខ្ញុំភ្លេចអស់ហើយ គ្មានបានស្គាល់ទេ ។

ដានី :	ភ្លេច?

ភាន :	ចាំ! ភ្លេច យូរឆ្នាំទៅវាភ្លេចអស់ ដឹងឈ្មោះអី ។

ដានី :	អត់ដឹងឈ្មោះ?

ភាន :	ចាំ!

ដានី :	ចុះមីងដល់ពេលមីងទៅធ្វើពេទ្យនឹង យើងស្នាក់នៅកន្លែងណា?

ភាន :	នៅនឹងត្រពាំងថ្មនឹង នៅក្នុងវត្ត ។

ដានី :	នៅក្នុងវត្ត?

ភាន :	ចាំ!

ដានី :	នៅក្នុងវត្តយើងសម្រាកក្នុងវត្តម៉ង?

ភាន :	ចាំ!

ដានី :	ដល់ពេលអ្នកជម្ងឺ គេឲ្យនៅកន្លែងណា?

ភាន :	នៅកន្លែងកុដិសាលាៗ២-៣សាលាគេ ។

ដានី :	សាលាគេ២-៣?

ភាន :	ចាំ!

ដានី :	ក្នុងវត្តនឹងម៉ង?

ភាន :	ក្នុងវត្ត ។

ដានី :	អ្នកជម្ងឺច្រើនយ៉ាងម៉េច ភាគច្រើនស្រីៗ ឬប្រុសៗ?

ភាន :	ស្រីប្រុសៗ ។

ដានី :	ស្រីប្រុសៗ ក្មេងៗ ក៏ចាស់ៗ?

ភាន :	អត់សូវមានចាស់ទេ ច្រើនតែក្មេងចល័តៗគេយកតែក្មេងៗ ។

ដានី :	ចំណាស់ណា អាយុប្រហែលប៉ុន្មាន?

ភាន :	ប្រហែល២០ជាង អីទៅ ១៨-១៩-២០ជាង ។

ដានី :	១៨-១៩ អត់មានចាស់?

ភាន :	បើចាស់នៅក្នុងភូមិ ចាស់នៅភូមិ ក្មេងគេឲ្យចល័ត ។

ដានី :	ចុះមីងកាលនឹងអ្នកដែលលើកទំនប់នឹងមកពីណាខ្លះទៅ?

ភាន :	អូ! ច្រើនណាស់ពីភ្នំពេញ ពីស្អីណាៗគ្រប់ច្រក ។

ដានី :	ប្រជាជនថ្មីអីនឹង?

ភាន :	ចា៎! ប្រជាជនថ្មី ។

ដានី :	ប្រជាជនថ្មី ច្រើនតែប្រជាជនថ្មី ហើយក៏មានប្រជាជនចាស់ទៅលើកទំនប់?

ភាន :	ធ្វើចាស់ ផ្លាស់ថ្មីខ្លះចូលគ្នាៗមិនដែលធ្វើការអី ក៏គ្នាយ៉ាប់ដង មិនដឹងធ្វើមេ៉ច ខ្ញុំស្រណោះ ។

ដានី :	ចុះមានស្លាប់ទេ?

ភាន :	ទេ! មិនសូវអីទេ ខ្លាចតែចេញពីខ្ញុំឈប់ដឹង ប្រហែលជាគេទៅឆ្ងាយៗពីខ្ញុំនៅកន្លែង ។ ខ្ញុំនៅតែកន្លែង មិនសូវទៅណាផង ។

ដានី :	ចុះមីងអត់ដែលដឹងថាស្លាប់អី មានស្លាប់អី?

ភាន :	មានខ្លះដែរ ។

ដានី :	ស្លាប់នឹងគេយកទៅកប់ណា?

ភាន :	យកទៅកប់នឹងដីត្រពាំងថ្មនឹង ។

ដានី :	កប់ក្នុងណា?

ភាន :	តាមត្រង់ណាទេ គេអ្នកប្រធានកប់ ខ្ញុំមិនដែលដឹង ។

ដានី :	មីងអត់ដែលដឹង?

ភាន :	ចា៎! គេអ្នកកប់ ។

ដានី :	ប្រធានឈ្មោះអី អ្នកប្រធានកប់?

ភាន :	វាមិនស្គាល់ទៀត មិនស្គាល់អាប្រធាន បើស្រុកផ្សេងគ្នា ។

ដានី :	កាលនឹងគេ មីងដូចថាមីងដឹងថា គេមានដាក់ផែនការអីក្នុងម្នាក់ៗលើកប៉ុន្មានម៉ែត្រគីបក្នុងម៉ាថ្ងៃ?

ភាន ៖ ម៉ាម៉ែត្រៗគីបម្នាក់ៗ ។

ដានី ៖ ម៉ាម៉ែត្រៗគីប?

ភាន ៖ ចា៎!

ដានី ៖ តែខ្ញុំជួបពូមីងខ្លះ គាត់ថាខ្លះ២ម៉ែត្រគីប ខ្លះ៣ម៉ែត្រគីប?

ភាន ៖ មិនទេ បើខាងគេនោះដីងខ្ញុំចល័តសុទ្ធតែម៉ាម៉ែត្រគីប ។

ដានី ៖ ម៉ាម៉ែត្រគីប?

ភាន ៖ ចា៎!

ដានី ៖ មិនមែន៣ម៉ែត្រគីប?

ភាន ៖ ខ្លះ៣ដីង បើចល័តរបស់ខ្ញុំគ្នាយ៉ាប់ៗ វាលើកតែក្មេងៗ ។

ដានី ៖ នេះខ្ញុំជួបពូមីងនៅខាងភូមិប៉ោយក្បៀង ខាងភូមិដើងវត្តអី គាត់ថាគេលើកកម្ទាំងទី១ ៣ម៉ែត្រគីប?

ភាន ៖ ប្រហែលកម្ទាំងទី១ដីង បើខ្ញុំមិនបានចុះជាប់កម្ទាំងទី១ផង ។ បើខាងនោះគេចុះជាប់ច្រើន ។

ដានី ៖ ចុះមីងអត់ដែលធ្លាប់ បើថាធ្វើពេទ្យស្រួលហើយ ចឹងលែងហត់ហើយ?

ភាន ៖ ចា៎! វាខ្ញុំធ្វើបានម៉ាឆ្នាំ បើធ្វើនឹងស្ពានស្រែងវាយ៉ាប់ខ្ញុំៗសុំមកផ្ទះ ដូចថាមិនឲ្យទៅទេ ឲ្យទៅនៅកន្លែងពេទ្យទៅ គ្រាន់ធ្វើ ។

ដានី ៖ ចុះមីង កាលជំនាន់នឹងដូចថាមានជម្ងឺហើម ជម្ងឺងងឹតមាន់ ខ្វាក់មាន់អី មាន?

ភាន ៖ មានៗខ្លះ ។

ដានី ៖ ហើមច្រើនដែរអត់?

ភាន ៖ ហើមខ្ញុំមិនសូវជួបដែលហើមទេ ដែលនៅពេទ្យ ។

ដានី ៖ ចុះខ្វាក់មាន់?

ភាន ៖ ខ្វាក់មាន់មានខ្លះ ។

ដានី ៖ ខ្វាក់មាន់ យើងព្យាបាលម៉េចទៅ?

ភាន ៖ មិនព្យាបាលទេ យប់ឡើងកុំឲ្យដើរទៅ ។

ដានី ៖ យប់ឡើងកុំឲ្យដើរទៅ?

ភាន ៖ ចា៎! កុំឲ្យដើរទៅ នៅកន្លែងនោះងងឹតមាន់នៅកន្លែងនោះកុំឲ្យដើរ ។

ដានី ៖ អានឹងដល់ពេលរួចទៅវាជាវិញ ហើយក៏អត់?

ភាន ៖ វាជាវិញ ជាមិនដែលបានឃើញវាងងឹត ។

ដានី ៖ ចុះមីងដែលខ្លាចមាន់ទេ?

ភាន ៖ ខ្ញុំមិនដែលបានទៅណា ។

ដានី ៖ អត់ដែលបានទៅណា?

ភាន ៖ អត់ដែលបានទៅណា ខ្ញុំនៅតែកន្លែង មើលតែដាំបាយដាំទឹកទៅ មើលអ្នកជម្ងឺ ។

ដានី ៖ ចុះកាលមីងទៅធ្វើទំនប់ត្រពាំងថ្មនឹង ដូចថា ពួថាកាលនឹងយើងពួថាមានកាលមុនអ្នកគ្រប់គ្រង នៅស្រុកភូមិយើងផ្សេង ដល់ពេលក្រោយមកមានពួកនិរតីចូលមក?

ភាន ៖ ចា៎!

ដានី ៖ កាលនឹងមីងអាច?

ភាន ៖ និរតីវាចូលមក ភូមិយើងខ្មែរមានពិបាកអី គេកាន់កាប់ហើយខ្ញុំនៅស្ងៀមទៅ គេគ្រាន់តែ មើលគេបញ្ជាយើងទៅ ។

ដានី ៖ ប៉ុន្តែយ៉ាងម៉េចដែរ មានការផ្លាស់ប្តូរគម្មាភិបាលចាស់នឹងគេយកទៅណា ហើយម៉េចបាន ពួកនិរតីគេមកថ្មីនឹង?

ភាន ៖ គេយកទៅណា យើងក៏នៅទៅ ធ្វើនឹងគេទៅ គេឲ្យធ្វើក៏ធ្វើ ។

ដានី ៖ តែយើងអ្នកប្រធានៗពីមុនៗមកគេយកទៅណាទៅ?

ភាន ៖ ហ្នឹងគេទម្លាក់ចោល ក៏គេធ្វើម្តងទៅ យើងក៏ធ្វើកូនក្រុមគេលើកនេះលើកនោះទៅមើលគេ ដាក់បញ្ជាទៅណាក៏ចេះតែទៅ ។

ដានី ៖ ចុះប្រធានមកពីខាងនិរតីថ្មីឈ្មោះអីទៅ?

ភាន ៖ អូ! រិតតែមិនស្គាល់ណាស់ទៅទៀត ។

ដានី ៖ អត់ស្គាល់?

ភាន ៖ ចា៎! អត់ស្គាល់ ។

ដានី ៖ ចុះមីងកាលជំនាន់ឲ្យនោះ មីងធ្លាប់ទៅលេងស្រុកទេ កាលមីងនៅត្រពាំងថ្ម?

ភាន ៖ ខ្ញុំមកសុំគេមកលេងម៉ែម្តងៗ ។

ដានី ៖ មកលេងម្តងៗដែរ?

ភាន ៖ ចា៎!

ដានី ៖ គេអត់ថាអី?

ភាន ៖ ទេ! សុំគេ ។

ដានី ៖ សុំពីណា មីងសុំពីណា?

ភាន ៖ សុំប្រធានៗដែលគេឈ្មោះអី ប្រធានពេទ្យ ។

ដានី ៖ សុំប្រធានឈ្មោះអី?

ភាន ៖ មិនស្គាល់ឈ្មោះគេទេ គ្រាន់តែហៅគេបងៗ អើយខ្ញុំសុំទៅមើលម៉ែខ្ញុំទៅដេកម៉ាយប់១-២ យប់ សុំ២យប់ គេថាឲ្យមក២យប់ មក២យប់ទៅវិញ ។

ដានី ៖ មក២យប់ទៅវិញទៅ?

ភាន ៖ ចាំ!

ដានី ៖ ចុះមីងកាលជំនាន់នឹង មីងដែលឮឈ្មោះយាយខែមទេ?

ភាន ៖ ឮតែហៅយាយខែមៗ ដឹងណា ។

ដានី ៖ ដែលឮគេហៅយាយខែមៗដែរ?

ភាន ៖ ឮ ។

ដានី ៖ យាយខែម កាលនឹងធ្លាប់ឃើញមុខគាត់ទេ?

ភាន ៖ អឺ! ភ្លេចអស់ហើយ មុនសូវបានចុះជាមួយគាត់ គេអ្នកធំៗគ្នាគាត់ ។

ដានី ៖ ប៉ុន្តែមីងធ្លាប់ជួប ធ្លាប់និយាយទល់ជាមួយគាត់ដែរ?

ភាន ៖ បានទល់ខ្លះនោះឯង គាត់ប្រជុំម្តងៗ ក៏ទល់ខ្លះ ។

ដានី ៖ ប្រជុំជាមួយគាត់ដែរ?

ភាន ៖ មកមើលគាត់ ប្រជុំរឿងធ្វើការងារ លោតផ្លោះតិច ។

ដានី ៖ យាយខែមរៀងគាត់ម៉េច?

ភាន ៖ គាត់ខ្មៅ ទាប ។

ដានី ៖ ខ្មៅ ទាប ធាត់ហើយក៏ស្អម?

ភាន ៖ គាត់ធម្មតា ។

ដានី ៖ ធម្មតា?

ភាន ៖ ធម្មតាប៉ុននឹងទៅ ។

ដានី ៖ ខ្មៅ ទាប មិនជាធាត់ទេ?

ភាន ៖ ចាំ! មិនធាត់ទេ ។

ដានី ៖ មិនស្អម?

ភាន ៖ នោះគាត់មកប្រជុំៗម្តងៗធ្វើការងារអីខ្លះ ។

ដានី ៖ គាត់កាលនោះ យាយថែម គាត់ធ្វើអី?

ភាន ៖ គាត់ធ្វើប្រធាន ។

ដានី ៖ ប្រធាននៅ?

ភាន ៖ ប្រធាននៅនេះ ។

ដានី ៖ ប្រធាននៅណា?

ភាន ៖ នៅនឹងស្រុកនេះឯង ។

ដានី ៖ ស្រុកណា?

ភាន ៖ ស្រុកព្រះនេត្រព្រះនេះ ។

ដានី ៖ ប្រធានស្រុកព្រះនេត្រព្រះ?

ភាន ៖ ចា៎!

ដានី ៖ ចុះនៅត្រពាំងថ្ម គាត់អ្នកគ្រប់គ្រងដែរអត់ទេ?

ភាន ៖ គាត់កាលនោះ មិនទាន់មកទេ ពុំតែគេហៅយាយថែមៗ ដល់មកប្រជុំគេហៅប្រជុំនឹងព្រៃមាន់នឹងអី ក៏គាត់មក ក៏ខ្ញុំឃើញគាត់ថានេះយាយថែមក៏នៅនឹងគាត់ទៅ យើងក៏អង្គុយស្ដាប់គេទៅ ក៏គេឲ្យគាត់ធ្វើការឲ្យ ។

ដានី ៖ កាលនឹងប្រជុំនៅព្រៃមាន់?

ភាន ៖ ចា៎!

ដានី ៖ មិនមែនប្រជុំនៅត្រពាំងថ្ម?

ភាន ៖ ត្រពាំងថ្មខ្លះព្រៃមាន់ខ្លះ ខ្ញុំមិនសូវដែលបានទៅទេ ។

ដានី ៖ អូ! គាត់ទៅប្រជុំនៅត្រពាំងថ្មដែរ?

ភាន ៖ ចា៎!

ដានី ៖ មីងបានចូលរួមប្រជុំជាមួយគាត់ប៉ុន្មានដង?

ភាន ៖ បាន២ដងប៉ុននោះឯង ។

ដានី ៖ បាន២ដង?

ភាន ៖ ចា៎!

ដានី ៖ គាត់និយាយថាម៉េចខ្លះពេលប្រជុំ?

ភាន ៖ អឺ! ភ្លេចអស់ដឹងនិយាយថាម៉េចទេ ។

ដានី ៖ អាចចាំខ្លះដូចថាពេលប្រជុំគាត់និយាយថាម៉េចទៅ បើ?

ភាន ៖ គាត់និយាយថា ធ្វើការជឿនលឿន លោតផ្លោះអីទៅ គាត់និយាយ ។

ដានី ៖ ធ្វើការជឿនលឿនលោតផ្លោះ?

ភាន ៖ ចាំ! ឲ្យលោតផ្លោះ ឲ្យលោត ។

ដានី ៖ យើងម៉េច យើងលោតផ្លោះ បានន័យយើងខំធ្វើឲ្យវាលឿន?

ភាន ៖ ចាំ! ឲ្យលឿន ឆាប់រួច ។

ដានី ៖ វាលឿនជាងយើងរត់ទៅទៀត បើយើងផ្លោះ ។

ភាន ៖ (សើច) ។

ដានី ៖ ចុះស្អីទៀតដែរ គាត់មានក្រៅពីអាជឿនលឿន ក្រៅពីលោតផ្លោះនឹង?

ភាន ៖ អស់ហើយ មិនមានអីទៀតទេ អត់ប៉ុននឹងឯង ។

ដានី ៖ ចុះយាយថែម គាត់កាចហើយស្លូត?

ភាន ៖ គាត់ធម្មតា ខ្ញុំមិនដែលបានជួបគាត់ ចុះដាប់ជាមួយគាត់ៗមកប្រជុំម្តងៗ ខ្ញុំមិនដែលបាន ។

ដានី ៖ យាយថែមគាត់ស្គាល់មីងដែរអត់?

ភាន ៖ អត់ស្គាល់ទេ ។

ដានី ៖ អត់ស្គាល់?

ភាន ៖ ចាំ!

ដានី ៖ យាយថែមចំណាស់?

ភាន ៖ កាលនោះគាត់នៅចាស់ហើយ ។

ដានី ៖ គាត់ចាស់ៗជាងមីង?

ភាន ៖ ចាស់ប្រហែល៥០ហើយ យាយនឹង គាត់ចាស់ហើយ ។

ដានី ៖ ចាស់ដែលហើយ ចំណាស់ជាងមីង?

ភាន ៖ ចាំ!

ដានី ៖ គាត់ធ្វើប្រធានស្រុកព្រះនេត្រព្រះនឹង?

ភាន ៖ ទាំងអស់ គាត់ដើរចល័តដឹង មិនសូវដឹងផង ។

ដានី ៖ ចល័តអីដែរ?

ភាន ៖ ចល័តដែលយើងលើកទំនប់ លើកប្រឡាយអី ធ្វើស្រែចំការបំពេញផលស្អី សព្វមុខសព្វមាត់ ប៉ុនខ្ញុំមិនបានទៅនៅត្រពាំងថ្ម ប៉ុនតែនៅក្នុងផ្ទះ ។

ដានី ៖ ចុះមីងនៅត្រពាំងថ្ម បានរយៈពេលប៉ុន្មានដែរ?

ភាន : បានម៉ាឆ្នាំជាងនោះឯង យួនចូល ។

ដានី : បានម៉ាឆ្នាំជាងយួនចូល?

ភាន : ចា៎!

ដានី : ចុះកាលនឹងដូចថាអ្នកដែលធ្វើការរែកដីរែកអីនឹង យើងមកលេងផ្ទះ លេងអី គេឲ្យមកលេងដែរអត់ ដូចមីង១ថាយើងសុំគេមកលេងផ្ទះមកលេងម្ដាយអីបាន ចុះអ្នករែកដីគេឲ្យមកលេងដែរអត់?

ភាន : អត់ នារីយុវជនគេមិនឲ្យមកទេ ខ្លាចមិនទៅវិញ ។ បើខ្ញុំនៅកន្លែងនោះ គេឲ្យមកលេង២ថ្ងៃ ប៉ុនដឹងស្រុកនៅណាទេ នារី-យុវជន មិនស្គាល់គេផង ទៅលេងនៅណាបើស្រុកនៅភ្នំពេញ នៅស្អីនោះឆ្ងាយគ្នាទៅលេងណា មិនដឹងស្រុកស្រែគេ ។

ដានី : ចុះមីងកាលធ្វើពេទ្យនឹង អត់ដែលធ្លាប់បានទៅរៀនអីទេ អត់ដែលបានរៀនពេទ្យអី?

ភាន : ទេ! គេម៉េចបានឲ្យទៅរៀន ឲ្យតែប្រធានធំទៅរៀន យើងគ្រាន់តែគេបង្ហាប់២-៣ថ្ងៃយើងចាំបានទៅ អីទៅភ័យអី ងាប់ចោល រស់ក៏យកទៅពេទ្យ(សើច) ក៏វាមិនដែលមានខូចខាតអីទេ មិនបាច់ទៅគិតគូរដូចសព្វថ្ងៃទៅ...(ស្ដាប់មិនបាន) ទៅរៀនទៅចាក់គេងាប់ពិបាកសងគេរាប់ណារាប់ណៃ កាលនោះអ្នកណាងាប់រស់ទៅ អ្នកណាជាក៏ជាទៅ ។

ដានី : ចឹងកាលជំនាន់នឹង យើងទៅចាក់អីគេងាប់អត់បញ្ហាអីដែរ?

ភាន : ចា៎! មានបញ្ហាអី ។

ដានី : បើឥឡូវតែយើងចាក់ស្លាប់ គេឲ្យសង?

ភាន : អូ! សងដែរ ។

ដានី : ចុះមីងកាលនឹង ប្រធានស្រុកមុនយាយថែម ប្រធានស្រុកព្រះនេត្រព្រះយើងឈ្មោះអីទៅ?

ភាន : អត់ស្គាល់ផង សុទ្ធតែប្រធានមកពីឆ្ងាយៗ មិនដឹងឈ្មោះ ។

ដានី : ចុះឈ្មោះតាវ៉ាល់ តាមោងអី ដែលឮស្គាល់ឈ្មោះគាត់?

ភាន : សព្វថ្ងៃគាត់នៅណា តាវ៉ាល់ តាមោង ខ្ញុំដឹងថាស្គាល់ ប៉ុនមិនដឹងថាគាត់នៅត្រង់ណា ស្រុកគាត់ ។

ដានី : ប៉ុន្តែគាត់ធ្វើអី កាលនោះ?

ភាន : គាត់ធ្វើប្រធាន អនុប្រធាន ទាំងអស់ ។

ដានី : ប្រធាន អនុប្រធាន?

ភាន ៖ ចា៎!

ដានី ៖ គាត់ធ្វើប្រធាននៅណា?

ភាន ៖ ប្រធានចល័ត ។

ដានី ៖ ប្រធានចល័តនៅណា?

ភាន ៖ នៅតាមត្រពាំងថ្ម តាមស្ពានស្រែង ។

ដានី ៖ ស្ពានស្រែង តាវ៉ាល់ តាមោងនឹង?

ភាន ៖ នោះឯង ។

ដានី ៖ ចុះមីងមិញថាមីងអត់ស្គាល់ ដល់ពេលខ្ញុំទៅ?

ភាន ៖ ស្គាល់ ថាស្គាល់គាត់ចល័ត តានេះតាមោងតាអីចេះតែស្គាល់ៗចល័ត ។

ដានី ៖ ស្គាល់ៗ?

ភាន ៖ ចា៎! ឮតែគេហៅក៏ នោះឯង ។

ដានី ៖ ដែលឃើញមុខគាត់ទេ?

ភាន ៖ ឃើញតែមកម៉ាភ្លែត គេប្រធានដែលមកយូរ ។

ដានី ៖ តាវ៉ាល់ តាមោង?

ភាន ៖ ចា៎!

ដានី ៖ នឹងគាត់នៅមុនយាយចែម ឬក៏គាត់នៅជាមួយយាយចែម?

ភាន ៖ ដូចជាមុន ហើយក្រោយ ប៉ុនឃើញតែម្តង ខ្ញុំមិនដែលបានទៅ ឲ្យតែឃើញគាត់មកតែម្តង ទាំងអស់គ្នា ក៏មិនដឹងណាមុនក្រោយ មិនសូវយកចិត្តទុកដាក់ទេ តែខ្លាច ។

ដានី ៖ ខ្លាច?

ភាន ៖ ចា៎!

ដានី ៖ ចុះដូចប្តីមីង គាត់ធ្វើការជាមួយតាវ៉ាល់ តាមោងនឹងដែរ ជាមួយយាយចែមដែរ ហើយក៏ យ៉ាងម៉េច?

ភាន ៖ អត់ដែលបានធ្វើផងយាយចែមយាយអី ។

ដានី ៖ បាទ?

ភាន ៖ អត់ដែលបានធ្វើ យាយចែមយាយអីអត់ដែលបានធ្វើទេ គាត់គ្រាន់តែប្រធានកងប្រធាន ក្រុមគេឲ្យវាស់ក៏គាត់វាស់ កងធំ មិនដែលបានស្គាល់ទេ ។

ដានី ៖ ប៉ុន្តែដូចថាគាត់វាស់អីចឹង យើងដើរជាមួយ យើងវាស់ជាមួយពួកគាត់នឹងដែរ?

ភាន ៖ ខ្ញុំមិនដែលបានឃើញផង ។

ដានី ៖ អត់ដែលបានឃើញ?

ភាន ៖ ចា៎! ខ្ញុំនៅតែកន្លែង ។

ដានី ៖ អត់ដែលសួរគាត់?

ភាន ៖ អត់ដែលបានសួរផង ដើរហើយក៏បែក សម័យនោះដែលប្ដីប្រពន្ធដែលបានដើរជាមួយគ្នាស្រួល ភារកិច្ចក៏ភារកិច្ចគេ ឃើងក៏ឃើង ដែលហ៊ាននិយាយអីខ្លាច ។

ដានី ៖ ចឹងមីងនៅធ្វើពេទ្យនឹងរហូត អត់មានផ្លាស់ទៅណាទេ នៅកន្លែងត្រពាំងថ្មនឹង?

ភាន ៖ នៅម៉ាឆ្នាំរហូត យួនចូល ។

ដានី ៖ ធ្វើពេទ្យរហូតអត់មានផ្លាស់អីទៅណាៗម៉ាឆ្នាំ?

ភាន ៖ អត់ទេ អត់បានទៅណាទេ ម៉ាឆ្នាំរហូត ។

ដានី ៖ ម៉ាឆ្នាំនឹង ដាំបាយផង ចាក់ថ្នាំផង បែកថ្នាំផង?

ភាន ៖ ចា៎! នៅតែក្នុងនឹងហើយ អត់បានទៅណាទៅណែ ។

ដានី ៖ មីងដែលស្ដីឲ្យអ្នកជម្ងឺ?

ភាន ៖ ទេ! ខ្ញុំគិតតែពីស្រណោះ ដែលមិនហ៊ានស្ដីទេ ។

ដានី ៖ ស្រណោះម៉េច?

ភាន ៖ ស្រណោះដែលគ្នាអត់ អាណិតអំបិលម៉ាចឹប បាយម៉ាចាន ស្រណោះក្នុងខ្លួនដែលខ្លួនឯងអត់ដែរ បេះតែស្រណោះហើយអត់មានស្ដីអីទេ ស្រណោះកូនគេក៏ដូចកូនឯងច្រើនតែមកពីអ្នក ភ្នំពេញ ស្អាតៗណាស់ មកក៏ស្រណោះ ចុះគ្នាមិនដែលត្រូវថ្ងៃ ។ ម្នាក់ត្រូវថ្ងៃឡើងក្រហម ទៅម្ងប់ទៅ ឲ្យទៅម្ងប់ ។

ដានី ៖ ស្រណោះគេដែរ?

ភាន ៖ ចា៎! ស្រណោះ ។

ដានី ៖ មីងមានស្គាល់ឈ្មោះខ្លះដែលកាលនោះ ប្រជាជនថ្មី?

ភាន ៖ អត់បានស្គាល់ទេ ។

ដានី ៖ អត់ស្គាល់?

ភាន ៖ មិនបានស្គាល់ទេ ។

ដានី ៖ ចុះពេលដែលយួនចូលមក កាលនឹងមីងនៅកន្លែងណា ពេលយួនចូលមកដល់?

ភាន ៖ មកយួនចូលមក ខ្ញុំនៅត្រពាំងថ្ម គេថាចូលមកៗហើយៗយួនចូលមកហើយក៏រៀបសាក់ការដូរចេញរៀងខ្លួន ។

ដានី ៖ ចេញមកណា?

ភាន ៖ ចេញមកស្រុក ។

ដានី ៖ មកស្រុកយើងនៅនឹងម៉ង?

ភាន ៖ ចា៎!

ដានី ៖ ចុះអត់រត់ទៅតាមគេទេ?

ភាន ៖ ខ្ញុំទៅតាមបានម៉ាឆ្នាំមកវិញ ។

ដានី ៖ មីងទៅតាមគេបានម៉ាឆ្នាំដែរ?

ភាន ៖ ចា៎!

ដានី ៖ ចុះមីងអាទំនប់ត្រពាំងថ្មនឹង ដល់ពេលយួនចូលមកធ្វើអត់ទាន់ហើយទេ?

ភាន ៖ ហើយអស់ហើយ ។

ដានី ៖ ហើយអស់ហើយ?

ភាន ៖ ចា៎!

ដានី ៖ ចុះមីងនៅធ្វើអីទៀត បើហើយអស់ហើយ?

ភាន ៖ ទេ! ដែលយួនចូលមកគេហើយអស់ហើយ គេនៅធ្វើអីៗធ្វើស្រែធ្វើអីទៀតស្ទូងដកទៀតទៅចល័ត ធ្វើចំការធ្វើអីទៀត ទម្រាំដល់យួនចូល ក៏គេចេញមករៀងខ្លួនទៅ ។

ដានី ៖ ចុះមីងចឹងពេលដែលយួនចូល មីងរៀបសាក់កាដូរ រត់ទៅបានម៉ាឆ្នាំដែរ?

ភាន ៖ រត់មកផ្ទះ ។

ដានី ៖ តែបានម៉ាឆ្នាំដែរ?

ភាន ៖ ទេ! មិនទាន់បានម៉ាឆ្នាំទេ ដល់ខ្ញុំរត់មកនេះ គ្រួសារខ្ញុំនេះគេយកមកដែរ ។

ដានី ៖ យកទៅណា?

ភាន ៖ យកទៅនៅភ្នំឆ័ត្រ ។ ដែលស្គាល់ភ្នំឆ័ត្រ ។

ដានី ៖ ឮភ្នំឆ័ត្រ នៅខាងព្រំដែន ខាងខ្មែរខាងអីនោះ ។

ភាន ៖ ចា៎! នោះឯង ដល់ខ្ញុំទៅបានប្រហែល២ខែ ៣ខែ ក៏ខ្ញុំបបួលគ្នាមកវិញ ក៏មកៗទៅជួនក៏នៅៗទៅ យើងមកហើយ យើងមិនទៅធ្វើអី ។

ដានី ៖ អូ! មីងរត់ទៅដល់ភ្នំឆ័ត្រដែរ ២នាក់ប្ដីប្រពន្ធ ដល់ពេលនេះទៅមីងមកត្រឡប់មកផ្ទះវិញ?

ភាន ៖ ចា៎!

ដានី ៖ មកផ្ទះវិញ គេអត់ថាអីទេ?

ភាន ៖ អត់ទេ ។

ដានី ៖ គេអត់មានយកទោសយកពៃរ៍?

ភាន ៖ អត់ទេ គេចែកដីស្រែឲ្យខ្ញុំៗមានរបបស្រែត្រឹមត្រូវ ។

ដានី ៖ មានរបបស្រែ មានអីត្រឹមត្រូវ?

ភាន ៖ ចា៎! មកវិញ ។

ដានី ៖ យួនវាអត់ថាអី?

ភាន ៖ ទេ! វាអត់ថាទេ ។

ដានី ៖ យើងចូលមកសារភាពៗអី?

ភាន ៖ ចា៎! សារភាពៗនឹងប្រធាននៅជប់យើង ។

ដានី ៖ នៅជប់ណាវី?

ភាន ៖ ចា៎! មកគេបើករបបឲ្យស៊ី ចា៎!គេហៅជប់ មកគេបើករបបឲ្យស៊ីទៀត ពួកនគរបាល ។

ដានី ៖ ចុះមីងម៉េចបានមីងត្រឡប់មកផ្ទះវិញ អត់តស៊ូជាមួយពួកខ្មែរក្រហមទៀត?

ភាន ៖ វាអត់ស្រួល ព្រោះគ្រាប់បន្តក់ច្រើនណាស់ ។ យួនវាបន្តក់ទៅណា ក៏ម៉ែឪខ្ញុំទៅយកមកវិញផង ក៏ខ្ញុំនឹកឃើញថា នៅតស៊ូព្រោះមិនបានប្រយោជន៍អី មកផ្ទះមកគេចែកដីស្រែគេឲ្យទៅ ក៏សុទ្ធតែបងប្អូនគេស្គាល់ ទៅក៏ពេលឈប់គេបើករបបឲ្យហូបត្រឹមមិនទាន់ឈប់ដែលយើង ធ្វើស្រែបាន និយាយឲ្យត្រង់ទៅ យើងអ្នកល្អ ។

ដានី ៖ ចុះមីងមកចឹង អត់ខ្លាចខាងខ្មែរក្រហមគេខឹង គេចាប់មីង?

ភាន ៖ ទេ! អត់ទេ សុំគេមក គេឲ្យមកស្រួលកាលសម័យនោះ ។

ដានី ៖ សុំគេមក គេឲ្យមកស្រួលដែរ?

ភាន ៖ ចា៎!

ដានី ៖ សុំពីណាកាលនឹង មីងសុំ?

ភាន ៖ សុំកាលនោះឈ្មោះតានុញៗ គាត់ឲ្យមកស្រួល ។

ដានី ៖ សុំ គាត់ឲ្យមកស្រួលដែរ?

ភាន ៖ ចា៎! ឲ្យមកទាំងប្ដីប្រពន្ធ មកគេចែករបបស្រែ បានរបបស្រែក៏ឈប់ទៅ មិនពិបាកទៅណាទៀតទៅ ។ សព្វថ្ងៃ ប្ដីក៏បែកបានប្រពន្ធទៀត ខ្ញុំអត់កូន ។

ដានី ៖ ចុះគាត់បែកពីមីងឆ្នាំណា?

ភាន ៖ អូ! យូរហើយ ប្រហែល២០ជាងហើយ ២០ឆ្នាំហើយ។

ដានី ៖ ប្រហែល២០ឆ្នាំហើយ?

ភាន ៖ ចាំ! តាំងពីខ្ញុំមកពីភ្នំឆ័ត្រ បានម៉ាឆ្នាំ គាត់សុំយកប្រពន្ធទៀត ដែលអត់កូន។

ដានី ៖ សុំ មីងឲ្យគាត់យកដែរ?

ភាន ៖ ឲ្យយក ខ្ញុំអត់កូន។

ដានី ៖ អត់ខឹងគាត់ទេ?

ភាន ៖ អត់ទេ សព្វថ្ងៃនៅ ខ្ញុំអត់ខឹង។

ដានី ៖ ឥឡូវគាត់រាប់អានមីងដែរ?

ភាន ៖ បងថ្ងៃយកទៅលេង ក៏ខ្ញុំទៅនិយាយនឹងគាត់ សួរសុខទុក្ខគ្នាទៅ ក៏ហីទៅ គេមានប្រពន្ធមួយទៀតហើយ ក៏ខ្ញុំសព្វថ្ងៃ ខ្ញុំចូលសីលហើយ ចូលសុំសីល។

ដានី ៖ ប៉ុន្តែគាត់ធ្លាប់មកលេងស្រុក មកលេងមីងដែរ?

ភាន ៖ មកលេងស្រុកគាត់មកលេងនេះឯង ផ្ទះសម្បែង។

ដានី ៖ តែគាត់មកលេងមីងដែលអត់?

ភាន ៖ ដែលមកលេង សព្វថ្ងៃខ្ញុំថាមិនបាច់ពិបាកទៅមកទេ វាលំបាករកឲ្យគ្នាស៊ីប្រពន្ធ២វាយ៉ាប់ សព្វថ្ងៃ គាត់ចាស់ហើយ អាយុ៦៨ស្មើគ្នានឹងខ្ញុំ។ ដល់គាត់ចាស់ហើយ ណាស់ហើយ ខ្ញុំក៏សុំសីលសុំអីទៅ។ ខ្ញុំចូលសីលអីទៅ យើងចាស់ហើយ យើងនៅតែថ្ងៃ បើសព្វថ្ងៃវាមិនទៀងទេ ដឹងជាស្លាប់ថ្ងៃណា។

ដានី ៖ ចឹងខ្ញុំដូចជាអស់សំនួរត្រូវសួរនាំមីងទៀតហើយ ចឹងមីងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំមីងទេ?

ភាន ៖ មានអីទេខ្ញុំអស់។

ដានី ៖ អស់ហើយ?

ភាន ៖ ចាំ! អស់ហើយ។

ដានី ៖ ចឹងខ្ញុំអរគុណមីងច្រើន ដែលចំណាយពេលផ្តល់បទសម្ភាសន៍...(ស្តាប់មិនបាន) អរគុណច្រើន។

«ចប់»